ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១០៤ ប្រក. កសក ៥

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- យោងតាមគោលនយោបាយពូជដំណាំនៅកម្ពុជា របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលដាក់ឲ្យប្រើប្រាស់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យទៅលើដំណើរការវាយតម្លៃ ធ្វើសេចក្តីសម្រេចចិត្តក្នុង ការបញ្ចេញប្រភេទពូជថ្មីនៃដំណាំ និងពិនិត្យទៅលើបញ្ជីឈ្មោះប្រភេទពូជដំណាំ។

**ប្រការ ២.-**

គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. | តំណាងអគ្គនាយកដ្ឋានកសិកម្ម | អនុប្រធាន |
| ៣. | តំណាងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | អនុប្រធាន |
| ៤. | តំណាងនាយកដ្ឋានកសិ-ឧស្សាហកម្ម | សមាជិក |
| ៥. | តំណាងវិស័យឯកជនធ្វើអាជីវកម្មពាក់ព័ន្ធនឹងពូជដំណាំ | សមាជិក |
| ៦. | តំណាងក្រុមផលិតពូជដំណាំ | សមាជិក |
| ៧. | តំណាងនាយកដ្ឋានជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានកសិកម្ម | លេខាធិការ។ |

សមាសភាពគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៣.-**

គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំមានអាណត្តិរយៈពេល៥ឆ្នាំ ហើយសមាជិកដែលត្រូវតែងតាំងនៅក្នុងគណៈកម្មាធិការ ត្រូវមានបទពិសោធន៍ពាក់ពន្ធ័នឹងពូជដំណាំ។ គណៈកម្មាធិការនេះ អាចអញ្ជើញអ្នកមានបទពិសោធន៍ពាក់ពន្ធ័នឹងប្រភេទពូជដំណាំដែលត្រូវស្នើសុំបញ្ចេញឱ្យចូលរួមការប្រជុំ ប្រសិនបើមានការចាំបាច់។ អ្នកមានបទពិសោធន៍ពាក់ពន្ធ័ទាំងនោះ អាចចូលរួមផ្តល់មតិ យោបល់ ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោត ឬចូលរួមធ្វើការអនុម័តនោះទេ។

**ប្រការ ៤.-**

គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ មានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ពិនិត្យនិងសម្រេចបញ្ចេញប្រភេទពូជថ្មីនៃដំណាំ
- សម្រេចអំពីប្រភេទដំណាំដែលត្រូវដាក់ចូលក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិ
- សម្រេចអំពីប្រភេទពូជដំណាំដែលមានស្រាប់ណាខ្លះដែលត្រូវដាក់បញ្ចូលក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិលើកដំបូង
- ពិនិត្យនិងអនុម័តពិធីសារពិសោធន៍ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃរាល់ប្រភេទដំណាំ
- ចុះពិនិត្យទីតាំងពិសោធន៍នៅក្នុងដំណាក់កាលលូតលាស់នៃដំណាំ ដើម្បីតាមដានអំពីស្ថានភាពលូតលាស់ និងសម្តែងកម្មនៃពូជដែលកំពុងធ្វើការពិសោធន៍វាយតម្លៃនៅទីវាល តាមការចាំបាច់
- ទទួលមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធស្តីពីការប្រើប្រាស់និងគុណប្រយោជន៍នៃប្រភេទពូជដំណាំដែលបានចុះបញ្ជី។

**ប្រការ ៥.-**

គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំត្រូវជួបប្រជុំពិភាក្សាការងារយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ឬតាមការស្នើសុំ របស់ប្រធានគណៈកម្មាធិការ ជាការចាំបាច់។ ការសម្រេចរបស់គណៈកម្មាធិការនេះ ត្រូវផ្អែកលើការព្រមព្រៀងគ្នាជាឯកច្ឆន្ទ។ក្នុងករណីពុំអាចសម្រេចបានការព្រមព្រៀងជាឯកច្ឆន្ទត្រូវអនុម័តតាមគោលការណ៍ ៥០%(ភាគរយ)បូក១(មួយ)។

**ប្រការ ៦.–**

នាយកដ្ឋានជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានកសិកម្ម ត្រូវផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងបច្ចេកទេស ដល់គណៈកម្មាធិការបញ្ជេញប្រភេទពូជដំណាំ ដូចខាងក្រោម៖

- ប្រមូលចងក្រងនិងរៀបចំរាល់ព័ត៌មានដែលចាំបាច់អំពីប្រភេទពូជដំណាំដែលស្នើសុំបញ្ចេញឱ្យប្រើប្រាស់
- រៀបចំកិច្ចប្រជុំនិងឯកសារប្រជុំជូនដល់សមាជិកនៃគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំយ៉ាងតិច ១៥ថ្ងៃ មុនការប្រជុំ
- រៀបចំកំណត់ហេតុនៃការប្រជុំនីមួយៗរបស់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ
- ធ្វើបច្ចុប្បន្នភាពបញ្ជីប្រភេទពូជដំណាំ ដោយអនុលោមទៅតាមការសម្រេច និងការណែនាំរបស់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ
- រៀបចំរបាយការណ៍លទ្ធផលស្តីអំពីការសម្រេចរបស់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំជាក់ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីពិនិត្យនិងសម្រេចជាចុងក្រោយ។

**ប្រការ ៧.–**

ការចំណាយសម្រាប់ដំណើរការរបស់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំត្រូវផ្គត់ផ្គង់ ដោយថវិកាជាតិក្នុងគម្រោងថវិការបស់អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ថវិការបស់គណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ ក៏អាចទទួលបានពីប្រភពផ្សេងៗទៀត តាមរយៈជាជំនួយ ជាគម្រោងនានា ឬជាលក្ខណៈពាណិជ្ជកម្មផ្សេងៗ។

**ប្រការ ៨.–**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ០៧ ខែ កុម្ភៈ ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងមុខងារសាធារណៈ

-ដូចប្រការ៨

-ឯកសារ កាលប្បវត្តិ